គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - BCV - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CJR- CSD - CWCC - GENEROUS
HROTP – IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC – PDP - PJJ - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្ដីប្រកាសព័ត៌មាន

## គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមសំដែងការព្រួយបារម្ភជាខ្លាំងអំពីការងាររបស់ សហចៅក្រមស៊ើបអង្កេតសាលាក្ដីខ្មែរក្រហម

ភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២

ការមិនឯកភាពគ្នាដែលកំពុងបន្តរវាងសហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) លើការតែងតាំងលោកចៅក្រម Laurent Kasper Ansermet បានកាន់តែក្លាយជាក្ដីបារម្ភមួយ។ ពាក់ព័ន្ធនឹងបញ្ហានេះ យើងជឿជាក់ថាការអន្តរាគមន៍តាមរយៈឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាលើការតែងតាំងលោកចៅក្រម Kasper Ansermet នៅទីបំផុតរំលោភកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដែលមានចែងទាំងក្នុងច្បាប់កម្ពុជានិងច្បាប់អ.វ.ត.ក។ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) គឺជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដែលមានសមាជិកចំនួន២៣ សូមជំរុញរដ្ឋាភិបាលកម្ពុជាឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីជួយឲ្យមានការតែងតាំងសហចៅក្រមស៊ើបអង្កេតនៅអ.វ.ត.ក។ម៉្យាងវិញទៀត អង្គការសហប្រជាជាតិ និងម្ចាស់ជំនួយរបស់អ.វ.ត.ក ត្រូវតែធានាពីកត្តិសព្ទរបស់អ.វ.ត.កដោយការធ្វើការស៊ើបអង្កេតឯករាជ្យពាក់ព័ន្ធនឹងការប្រព្រឹត្តដោយសហចៅក្រមស៊ើបអង្កេត។ បើមិនដូច្នោះទេ មតិករបស់សាលាក្ដីនេះ ត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរជាមិនខាន។

ទីមួយ និងសំខាន់បំផុត គឺចៅក្រមបំរុងអាចនឹងត្រូវហៅឲ្យចូលនៅពេលមានប្រព្រឹត្តិការណ៍បន្ទាន់ និងជំនួសអតីតចៅក្រម។ ចេញពីទស្សនៈច្បាប់មួយ ពួកគាត់ត្រូវបានតែងតាំងរួចទៅហើយ នៅពេលត្រូវបានរៀបចំឲ្យធ្វើជា "ចៅក្រមបំរុង"។ យោងតាមមាត្រា២៥ និងមាត្រា២៦នៃច្បាប់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតបំរុងបរទេស បានត្រូវតែងតាំងក្នុងលក្ខណៈជាផ្លូវការរួចទៅហើយ។ យោងតាមមាត្រា២៧(៣) នៃច្បាប់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតបំរុង - តាមច្បាប់ - ជំនួសអតីតសហចៅក្រមស៊ើបអង្កេត ហើយត្រូវផ្ដល់កាតព្វកិច្ចឲ្យបំពេញតួនាទីរបស់ខ្លួន។ វាលេចឡើងយ៉ាងអាថិកំបាំងដែលថា ហេតុអ្វីចាំបាច់ត្រូវមានការតែងតាំងផ្លូវការមួយផ្សេងទៀត និងបានពន្យាពេលបន្តជាច្រើនខែ។ ប្រសិនបើការតែងតាំងបែបនេះគិតថាចាំបាច់នោះ វាគ្រាន់តែជាភាពផ្លូវការមួយ និងគ្រាន់តែអនុញ្ញាតឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបដិសេធចៅក្រមក្នុងករណីប្រព្រឹត្តខុសធ្ងន់ធ្ងរតែប៉ុណ្ណោះ។

ទីពីរ គឺសហចៅក្រមស៊ើបអង្កេត (ជាតិ និង អន្តរជាតិ) គួរតែធ្វើការរួមគ្នាក្នុងភាពចុះសម្រុងខាងវិជ្ជាជីវៈ ប្រកាន់ខ្ជាប់នូវការគោរពឯករាជ្យភាពតុលាការ និងនីតិរដ្ឋ។ នេះគឺជាបញ្ហាសំខាន់ខ្លាំងណាស់ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចាស់ៗនឿយណាយនឹងការពន្យាពេលជារឿយៗពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង០០៤ដែលមិនទាន់ចាត់ការ។ ការស៊ើបអង្កេតឯករាជ្យក្នុងការដោះស្រាយសំណុំរឿង០០៣និង០០៤ ត្រូវតែត្រូវបានធ្វើឡើង ហើយវាក៏ជាតួនាទីរបស់អង្គការសហប្រជាជាតិដាក់សំពាធលើរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការជ្រៀតជ្រែកនយោបាយនានា។ អង្គការសហប្រជាជាតិ គួរតែបំពេញការពាក់ព័ន្ធរបស់ខ្លួនក្នុងលក្ខណៈសកម្មជាងមុនបន្ថែមទៀត។

ទីបី គឺប្រព័ន្ធបច្ចុប្បន្នរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវតែទទួលរ៉ាប់រងលើដំណើរការកែទម្រង់ប្រព័ន្ធតុលាការមួយ។ ក្រសួងយុត្តិធម៌ មិនគួរចូលពាក់ព័ន្ធក្នុងការសម្រេចចិត្តនិងតម្លាភាពបន្ថែមអំពីដំណើរការជាតំរូវការចាំបាច់ច្រើននោះទេ។ ជាមួយនឹងកំណែទម្រង់នេះ យើងសូមជំរុញថា ពង្រាងនៃវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមិនទាន់ចាត់ការ ត្រូវតែធ្វើវិសោធនកម្មភ្លាមៗ ដើម្បីធានាការប្រព្រឹត្តមានប្រសិទ្ធិភាពនិងឯករាជ្យពេញលេញនៃតុលាការក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ការផ្តល់ការពាក់ព័ន្ធនៃសហចៅក្រមស៊ើបអង្កេតជាតិទៅក្នុងការសម្រេចចិត្តរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យើងសូមជំរុញឲ្យចៅក្រមជាតិចាក់ចេញពីឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ដោយសារតែតួនាទីពីរនេះហើយ ដែលលោកចៅក្រមមិនអាចអនុវត្តតួនាទីរបស់ខ្លួនដោយឯករាជ្យ។

ដូចនេះ យើងសូមជំរុញឲ្យរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបំពេញតួនាទីរបស់ខ្លួនទាក់ទងនឹងអ.វ.ត.កដោយស្មើភាពគ្នា ដោយយោងតាមស្មារតីកិច្ចព្រមព្រៀង។ សង្គមស៊ីវិលទាមទារឲ្យមានយុត្តិធម៌តាមរយៈតុលាការឯករាជ្យមួយ និងធុញទ្រាន់នឹងការរងចាំពាក់ព័ន្ធនឹងសំណុំរឿង០០៣និង០០៤។


*<u>សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:</u>*

| | | |
|---|---|---|
| លោក ធន សារាយ | ប្រធានសម្របសម្រួលCHRAC និង | |
| | ប្រធានសមាគមអាដហុក | ទូរស័ព្ទ: ០១៦ ៨៨០ ០៨៥ |
| លោក សុក សំអឿន | នាយកប្រតិបត្តិនៃអង្គការ CDP | ទូរស័ព្ទ: ០១២ ៩០១ ១៩៩ |
| លោក ហង្ស ឆាយា | នាយកប្រតិបត្តិនៃអង្គការ KID | ទូរស័ព្ទ: ០១២ ៨៦៥ ៩១០ |
| លោក រុន សារាយ | នាយកប្រតិបត្តិនៃអង្គការ LAC | ទូរស័ព្ទ: ០១២ ៨៣៨ ៣៩១ |
| លោក ម៉ាក ចំរើន | នាយកប្រតិបត្តិនៃអង្គការ KYA | ទូរស័ព្ទ: ០៩៧ ៨៨៨ ៥៧៧៧ |